# បម្រែបម្រួលសំណោរពាក្យ «សោយ» (ភាគ២)

ចំពោះពាក្យ «ស្វយ៑/ស្វយ» នៅសម័យមុនអង្គរនិងអង្គរ បានកម្លាយដោយផ្នត់ដែក [-អម់-] ឬ [-អង់-] បង្កើតបានជាពាក្យ «សំហ្វយ៑» ឬ «សង្វែយ/សំង្វយ៑» ដែលតាមការវិវត្តភាសាខ្មែរ ពាក្យនេះអាចក្លាយមកជាពាក្យ «សង្វើយ» ប៉ុន្តែពុំឃើញមាននៅក្នុងវចនានុក្រមខ្មែរឡើយ។ ពាក្យ «ស្វោយ» កាលបើកម្លាយដោយផ្នត់ដែក [-អង់-] បង្កើតបានជាពាក្យ «សង្វោយ» ដែលតាមវចនានុក្រមខ្មែរពន្យល់ពាក្យនេះមានន័យថា គ្រឿងសោយ ព្រះស្វោយ ឬសំណែនបូជាទេវតា។[១] នៅសម័យបុរាណ «សង្វែយ» (សង្វើយ/សង្វោយ) សំដៅដល់ដង្វាយដល់អាទិទេពជាដើម ដូចជា ស្វាសំវេយ៑ (K.១៣៧១) = ស្វាសង្វោយ គឺស្វាសម្រាប់ថ្វាយព្រះ។ នៅក្នុងសិលាចារឹកប្រាសាទដើមអង់មានបញ្ជាក់អំពីព្រះសង្វោយដូចឃ្លាថា៖ [...] •វ្រះសំវេយ៑សបថ្ងៃ៑រង្កោតជាយជ្ញ • ថ្លោង៤ • នំបុន៑ • សន្ទេកហ្វប៑វទិ • វទា • គ្រលេង៑ • ផុរិ • ផុរា • ធមាយ • កំបោ • បរមាន • ក្បិរ • តិលមោទ • (K.៩៩ មេទ្វារខាងជើង) ដែលអាចសម្រាយជាភាសាខ្មែរទំនើបថា៖ [...] ព្រះសង្វោយប្រចាំថ្ងៃ អង្ករសម្រាប់បូជាយជ្ញ៤ថ្លោង នំបុន សណ្តែកហូប វទិ វទា គ្រលេង ផុរិ ផុរា ធមាយ កំបោរ(?) បរិមាណទឹកដោះគោ ប្រេងក្រអូប។[២]

ថ្វីដ្បិតតែនៅក្នុងវចនានុក្រមខ្មែរ ពុំមានពាក្យ «សង្វើយ» ក្តី ប៉ុន្តែយើងឃើញមានពាក្យនេះប្រើជាស្ថាននាម ដែលជានាមឃុំមួយស្ថិតនៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប។ ម្យ៉ាងទៀត រណ្តាប់សែនឬសំណែនបានបាយសម្ងំបង្អែមជាដើម ដែលគេសែនឱ្យខ្មោចក៏ហៅថា បាយសង្វើយ។[៣] រណ្តាប់សំណែនក្នុងពិធីសំពះគ្រូរបាំនិងល្ខោន ក៏ហៅថា «សង្វើយ» ផងដែរ។ ចំណែកឯគ្រឿងរណ្តាប់សម្រាប់បូជាថ្វាយព្រះបិតរ នៅក្នុងកិច្ចពិធី

[១] វចនានុក្រមខ្មែរ ១៩៦៨: ១៤១២។

[២] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/9827 និង https://ams.com.kh/khmercivilization/detail/10051។

[៣] សូមមើល៖ https://web.facebook.com/watch/?v=269535627269732 និង https://web.facebook.com/watch/?v=420742382024971 ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ចាក់ទឹកដូងថ្វាយព្រះបិតរក្នុងព្រះបរមរាជវាំងក៏ហៅថា គ្រឿងសង្វោយ ឬ គ្រឿងសង្វើយ។ យើងឃើញថាពាក្យ «សង្វើយ» ពុំប្រើប្រាស់សម្រាប់មនុស្សរស់ឡើយ គេប្រើសម្រាប់រណ្តាប់សែនខ្មោច រណ្តាប់គ្រូ រណ្តាប់ថ្វាយវិញ្ញាណក្ខន្ធព្រះមហាក្សត្រ និងរណ្តាប់ថ្វាយទេវតា។

តាមរយៈការពិនិត្យខាងលើនេះ យើងឃើញកាន់តែច្បាស់ថា ពាក្យសៀម «สังเวย» ជាពាក្យយកពីខ្មែរបុរាណទៅប្រើប្រាស់ ដ្បិតពាក្យសៀមពុំមានកម្លាយដោយផ្ទត់ ដូចភាសាខ្មែរឡើយ។ ដូច្នេះ ពុំគួរមានមន្ទិលសង្ស័យថាពាក្យ «សង្វើយ» ដែលពុំមាននៅក្នុងវចនានុក្រមខ្មែរនោះ ជាពាក្យប្រើតាមសៀមឡើយ ប៉ុន្តែជាពាក្យដែលត្រូវបញ្ចូលក្នុងវចនានុក្រមខ្មែរនាគ្រាក្រោយៗទៀត។

ដូច្នេះ យើងអាចពិនិត្យជារួមបានថា ពាក្យ «សោយ» ជាពាក្យដែលមានប្រើតាំងពីសម័យមុនអង្គរ ដែលមានសំណេរជា «ស្វយិ» និងបន្តប្រើរហូតមកដល់សម័យអង្គរ។ នៅសម័យកណ្តាល ពាក្យនេះមានបម្រែបម្រួលមកជា «ស្វោយ» វិញ ដែលសង្កេតឃើញមាននៅលើសិលាចារឹក។ មកដល់ដើមស.វ.ទី២០ ពាក្យនេះចាប់ផ្តើមនិយមប្រើជា «សោយ» បន្តិចម្តងៗ រហូតស្ទើរតែលែងមានអ្នកស្គាល់ពាក្យ «ស្វោយ» នាពេលបច្ចុប្បន្ន។ ពាក្យ «ស្វយ» បានបង្កើតពាក្យថ្មីតាមរយៈផ្ទត់កម្លាយជា «សង្វេយ > សង្វើយ»។ ដូចគ្នាដែរ ពាក្យ «ស្វោយ» បង្កើតពាក្យថ្មីតាមរយៈផ្ទត់កម្លាយជា «សង្វោយ»។ ពាក្យ «ស្វោយ» ក្លាយសូរមកជា «សោយ» និងប្រហែលជាបង្កើតបានជាពាក្យកម្លាយមួយទៀតគឺ «ស្វាយ»។ ពាក្យ «ស្វាយ» នេះ ក៏ទំនងជាអាចជាពាក្យក្លាយសូរមកពីពាក្យ «សង្វោយ» ផងដែរ ដ្បិតយើងសង្កេតឃើញន័យរបស់ពាក្យ «ស្វាយ» និង «សង្វោយ» នេះ ដែលទាក់ទងគ្នានោះគឺសំដៅដល់គ្រឿងសោយ សំណែនសម្រាប់បូជាដល់អមនុស្ស មានទេវតា ខ្មោច។ល។

នៅក្នុងអត្ថបទនេះ ពុំទាន់សិក្សាលើទំនាក់ទំនងពាក្យ «ស្វយ» និងពាក្យ «ស៊ី/ឆី» នៅឡើយទេ ដ្បិតពាក្យទាំងនេះ មានទំនាក់ទំនងគ្នាដែលគួរតែលើកយកមកពិនិត្យមើលបន្ថែមទៀតនៅពេលក្រោយ៕

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## ឯកសារយោង

ព្រំ ម៉ល់

២០១៣. មូលដ្ឋាននៃសង្គមភាសាវិទ្យា (ដោយរៀបចំថ្មីនិងបន្គ្រប់បន្ថែម), ផ្សាយចេញលើកទី៤, ភ្នំពេញ។

ហ៊ុន ឈុនតេង

២០១៨. "សិលាចារឹកមកពីភូមិថ្មគ្រែ K.១៣៧១", ក្នុងកម្ពុជសុរិយា លេខ៤, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

### តារាងសម្រង់ពាក្យ

| សំណេរពាក្យបុរាណ | ស្រង់ចេញពីសិលាចារឹក |
|---|---|
| ស្វេយ៑ ស្វេយ | K.33: 35; K.139: B 17; K.175: S15 & W10; K.194: A10, 13 & 27; K.211: 5; K.214: B18; K.219: 2; K.230: C3; K.235: D4, 64 & 81; K.277: S14 & 15; K.292 (x4); K.324: S14; K.327: S15; K.330: S18; K.331: S20; K.342: W18; K.350: N3, 5 & 6; K.352: N39 & 43; K.413: A13 & B10; K.444: A4 & C13; K.467: 8; K.523: C22 & 26; K.583: B7; K.598: B2; K.697: B3, 26 & 27; K.705: 10 & 11; K.817: 15, 17 & 19; K.868: A3 & B7; K.956: 48; K.1065: 4 & 5 |
| ស្វោយ ស្វោ្យ | K.261: A20, K. 285: 17 & 21; K.301: 8, 18 (x2), 25 & 44; K.465: 12 & 15 |
| ស្វោយ្យ | IMA 13:29 |
| សោយ | K.261: B26, D26, E12 & E15; K.301: 46; K.303 No10: 12 |
| សំហ្វេយ៑ | |
| សំវេយ៑ | K.99: N26; K.349: 15 |
| សង្វើយ | K.143: A10; K.299: 5; K.315: N12; K.318: N13; K.353: S33; K.702: B12; K.1073 |

សំឡេងសម្ភាសអ្នកស្រុកជីផាត់ អំពី «សង្វើយ» ដោយលោក អាន រស្មី

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព




គំនូសបង្ហាញពីបម្រែបម្រួលសំណេរពាក្យ សោយ (ដោយ ហ៊ិន ឈុនតេង)




ពាក្យស្រង់ចេញពីសំណៅផ្ដិតសិលាចារឹក

អត្ថបទដោយៈ ហ៊ិន ឈុនតេង



បាយសង្វើយ ភូមិជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង (តំបន់អារ៉ែង) (រូបថតៈ អាន រស្មី)



ភូមិជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង រៀបបាយសង្វើយ សែនខ្មោចសាច់ញាតិ (រូបថតៈ អាន រស្មី)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



ពិធីថ្វាយគ្រឿងសង្វើយនៅមុខប្រាសាទបន្ទាយឆ្មារ (រូបថត៖ https://web.facebook.com/tatoultompong)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង